## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ២៣ ខែសីហា ឆ្នាំ២០១២

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 23-Aug-2012, 14:45
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើរបស់ អៀង សារី សុំស្តាប់ការបង្ហាញភស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី គី តួន លើកទីពីររបស់ ក.ស.ច.ស ដែលកើតមាននូវភាពមិនប្រក្រតី ដែលអាចនឹងចាត់ទុកថាជាការលេចឆ្លិនភ្លែក

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី អៀង សារី**
អាង ឧត្តម
Michael G. KARNAVAS

**ចម្លងជូន:**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម **និល ណុន**
ចៅក្រម **យូ ឧត្តរា**
ចៅក្រម **យ៉ា សុខន**
ចៅក្រម Silvia CARTWRIGHT
ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបម្រុង ធូ មន្នី

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) និងអនុលោមតាមវិធាន ៩៣ និង ២១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សូមស្នើឲ្យអង្គជំនុំជម្រះកោះហៅអ្នកបកប្រែផ្ទាល់មាត់ ដែលមានវត្តមាននៅពេលស្តាប់ចម្លើយសាក្សី រ៉ចាម តុន (“ភី ភួន”) ដែលបានធ្វើឡើងដោយ ក.ស.ច.ស លើកទីពីរ ដើម្បីផ្តល់ភ័ស្តុតាងនៅក្នុងសវនាការផ្ទាល់មាត់ជាសាធារណៈ ទាក់ទិននឹងកាលៈទេសៈនៃការស្តាប់ចម្លើយនេះ។ សំណើនេះមានសារៈសំខាន់ណាស់ ដោយសារតែមានភាពមិនប្រក្រតីយ៉ាងច្បាស់ក្រឡែត ពាក់ព័ន្ធនឹងការស្តាប់ចម្លើយ ភី ភួន លើកទីពីរ ដែលមេធាវីការពារក្តីបានលើកឡើងដោយផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1]។ ដោយផ្អែកទៅលើការពិភាក្សាក្រៅផ្លូវការជាមួយនឹងអ្នកបកប្រែផ្ទាល់មាត់ មេធាវីការពារក្តីមានក្តីបារម្ភយ៉ាងខ្លាំងអំពីសុចរិតភាពនៃកិច្ចស៊ើបសួរ និងសិទ្ធិរបស់ អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[2]។ ការថតសំឡេងនៃការស្តាប់ចម្លើយលើកទីពីរហាក់ដូចជាបង្ហាញថាវាជាទង្វើដែលមានការលេងល្ពិនល្ពែក៖ ការស្តាប់ចម្លើយដោយមានការរៀបចំដែលសំណួរ និងចម្លើយត្រូវបានរៀបចំឡើង ផ្អែកទៅលើការស្តាប់ចម្លើយ ដែលពុំបានថតសំឡេងកាលពីលើកមុន ហើយបន្ទាប់មកត្រូវបានអានដាក់ឧបករណ៍ថតសំឡេង ដើម្បីបំភ័ន្តភ្នែកថា ការថតសំឡេងនោះឆ្លុះបញ្ចាំងនូវការស្តាប់ចម្លើយពិតៗ ។ អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យមេធាវីការពារក្តីធ្វើជាសំណើលាយលក្ខណ៍អក្សរ ដើម្បីកោះហៅអ្នកបកប្រែផ្ទាល់មាត់ឲ្យផ្តល់ភ័ស្តុតាង[3] ដោយទទួលស្គាល់ថា កាលៈទេសៈនៃការស្តាប់ចម្លើយលើកទីពីររបស់ ភី ភួន គឺជា “បញ្ហាសំខាន់ មិនមែនជាបញ្ហាធម្មតាទេ”[4]។ អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមដាក់សំណើនេះ ដើម្បីកោះហៅអ្នកបកប្រែផ្ទាល់មាត់ឲ្យមកធ្វើសក្ខីកម្មដោយមានការធ្វើសច្ចាប្រណិធាន ទាក់ទិន ទៅនឹងរបៀបដែលការស្តាប់ចម្លើយ ភី ភួន លើកទីពីរត្រូវបានធ្វើឡើង។

---

[1] ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/96 ទំព័រ ៦១-៦៤ (ភាសាអង់គ្លេស)។

[2] អនុលោមតាមវិធាន ៧៦(៧) ទោះបីជាមេធាវីការពារក្តីទទួលស្គាល់ថាដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនីតិវិធីយ៉ាងណាក៏ដោយ ក៏នៅក្នុងករណីនេះ វិធីសាស្ត្រមិនត្រឹមត្រូវ និងខុសប្រក្រតី ដែលធ្វើឡើងដើម្បីស្តាប់យកចម្លើយ ភី ភួន នោះ ហាក់ដូចជាហួសពីវិមតិសង្ស័យ ហើយ ដូចបានលើកឡើងនៅក្នុងសំណើនេះ បង្កើតបាននូវមន្ទិលចំពោះការថ្លឹងថ្លែងទៅលើសក្ខីកម្មរបស់គាត់។

[3] ប្រតិចារឹក ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/100.1 ទំព័រ ៨៦ (ភាសាអង់គ្លេស)។

[4] ដូចយោងខាងលើ។

## I. សាវតារ

១. នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្នុងអំឡុងពេលនៃការពិនិត្យដោយយកចិត្តទុកដាក់ និងក្នុងខណៈដែលខ្លួនកំពុងត្រៀមរៀបចំសម្រាប់សវនាការ មេធាវីការពារក្តីបានស្នើឲ្យអង្គភាពបកប្រែភាសា ("ITU") ធ្វើប្រតិចារឹកការថតសំឡេងនៃការស្តាប់ចម្លើយ ភី ភួន ទាំងពីរលើក ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស។ ជាថ្មីម្តងទៀត នៅថ្ងៃទី ២០ ខែ កក្កដា មេធាវីការពារក្តីបានស្នើឲ្យ ITU ធ្វើប្រតិចារឹកការថតសំឡេងនៃការស្តាប់ចម្លើយ ភី ភួន លើកទីពីរ ដែលធ្វើឡើង ដោយ ក.ស.ច.ស។ យើងទទួលបានប្រតិចារឹកនោះ នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២។

២. នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ មុនពេលដែលសាក្សីចូលមកបង្ហាញខ្លួននៅពេលរសៀល និងដោយពុំទាន់មានវត្តមានសាក្សីនៅឡើយនោះ មេធាវីការពារក្តីបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងចាប់អារម្មណ៍អំពីការស្តាប់ចម្លើយ ភី ភួន ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៨។ មេធាវីការពារក្តីបានចង្អុលបង្ហាញដល់អង្គជំនុំជម្រះសាលាដំបូងថា ដោយមានការពិនិត្យយ៉ាងយកចិត្តទុកដាក់ សមាជិកក្រុមដែលនិយាយភាសាខ្មែរ បានពិនិត្យឡើងវិញនូវខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ភី ភួន ដែលធ្វើឡើងដោយ ក.ស.ច.ស ក្នុងអំឡុងការរៀបចំការសាកសួរដេញដោលសាក្សីរូបនេះ[5]។ ការពិនិត្យឡើងវិញនោះបានបង្ហាញឲ្យសមាជិកក្រុមនិយាយភាសាខ្មែរដឹងថា ភី ភួន អានចម្លើយចេញពីឯកសារតែម្តង[6] ដែលមានន័យថា ការស្តាប់ចម្លើយនោះ មិនមែនជាការសន្ទនាទេ គឺគេអានសំណួរ ហើយឲ្យគាត់អានចម្លើយហ្នឹងមកវិញ"[7]។ ដោយផ្អែកលើការពិនិត្យឡើងវិញនូវខ្សែអាត់សំឡេងនេះ មេធាវីការពារក្តីបានស្នើឲ្យធ្វើប្រតិចារឹកខ្សែអាត់សំឡេងនេះទៅជាភាសាអង់គ្លេស[8]។ មេធាវីការពារក្តីបានកត់សម្គាល់ថា ខ្សែ

---

[5] ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/96.1 ទំព័រ ៦១-៦២ (ភាសាអង់គ្លេស)។

[6] ដូចយោងខាងលើ ទំព័រ ៦២ (ភាសាអង់គ្លេស)។

[7] ដូចយោងខាងលើ។

[8] មេធាវីការពារក្តីបានទទួលប្រតិចារឹកជាភាសាអង់គ្លេសនៅមុនពេលចាប់ផ្តើមបន្តិចនៃសវនាការពេលរសៀល ហើយបានលើកនូវបញ្ហានេះដល់អង្គជំនុំជម្រះសាលាដំបូងភ្លាមបន្ទាប់ពីចាប់ផ្តើមដំណើរការនីតិវិធី។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/96.1 ទំព័រ ៦៣ (ភាសាអង់គ្លេស)។

អាត់សំឡេងនេះ មានរយៈពេល "តែ ១០ ទៅ ១២នាទីទេ" ហើយប្រតិចារឹកកត់ត្រាតែ "បួនទំព័រ"[9]។ ខ្លឹមសារ នៃប្រតិចារឹកបួនទំព័រនេះគឺស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយ (E3/63)។ មេធាវីការពារក្តីបានលើកសំណួរថាតើមានអ្វីកើតឡើងក្នុងអំឡុងផ្នែកនៃការស្តាប់ចម្លើយ ដែលមិនបានថតសំឡេងនោះ និងថាតើ ភី ភួន ត្រូវបានគេផ្តល់ចម្លើយឲ្យគាត់ ហើយឲ្យគាត់អានចម្លើយហ្នឹងទៅនឹងសំណួរ ដែលគេសួរគាត់ ឬយ៉ាងណា[10]។

៣. បន្ទាប់ពីបានស្តាប់សេចក្តីសង្កេតរបស់មេធាវីការពារក្តីរួចមក លោកប្រធាន និល ណុន បានសួរ ភី ភួន អំពីការស្តាប់ចម្លើយរបស់ ក.ស.ច.ស៖

> នៅក្នុងដំណើរការប្រព្រឹត្តទៅ នៃការសួរធ្វើសម្ភាសជាមួយលោកកាលណោះ តើលោកនៅចងចាំបាន ដែរទេថា ការធ្វើសម្ភាសនោះគឺគេតាំងសំណួរចំពោះលោក ឲ្យលោកឆ្លើយ ឬក៏គេធ្វើនីតិវិធីផ្សេងពីនេះ បានន័យថា គេសួរ ឬគេប្រាប់ចម្លើយដែលលោកត្រូវតែឆ្លើយតាមគេអីចេះអីចុះដែរឬទេ ឬក៏យ៉ាងម៉េច?[11]

ភី ភួន បានឆ្លើយតបថា គាត់ "បានរៀបរាប់អ្វីដែលខ្ញុំបាន បានជួបប្រទះ ហើយខ្ញុំរៀបរាប់តាមហ្នឹង តាំងពីដើមហ្នឹង គឺថា តាំងពី៦៧មកៗ ខ្ញុំរៀបរាប់ហូរហែមកអីចឹង"[12]។

៤. បន្ទាប់មក លោកប្រធាន និល ណុន បានសួរថា ៖

> អីចឹងចុះពេលគេសួរ គេមានតាំងសំណួរសួរ សួរឆ្លើយៗដែរឬទេ ពេលដែលអ្នកស៊ើបអង្កេតសួរលោកមួយសំណួរ ហើយលោកត្រូវឆ្លើយតបទៅនឹងសំណួរហ្នឹង បន្ទាប់មកគេតាំងសំណួរផ្សេងទៀតមួយ បន្ទាប់ទៀត ហើយលោកឆ្លើយអីចឹង ឬក៏ប្រព្រឹត្តទៅតាមនីតិវិធីខុសពីនេះ?[13]

ភី ភួន បានឆ្លើយតបថា ៖ "គាត់លើកសំណួរទៅ ខ្ញុំឆ្លើយ។ ខ្ញុំឆ្លើយសំណួររបស់គាត់ហ្នឹងទៅ។ អ្នកដែលស៊ើបអង្កេតហ្នឹងគាត់លើកឡើងសំណួរហ្នឹងទៅ ស្អីដែលខ្ញុំដឹង ខ្ញុំឆ្លើយតាមហ្នឹងទៅ"[14]។

---

[9] ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/96.1 ទំព័រ ៦២ (ភាសាអង់គ្លេស)។

[10] ដូចយោងខាងលើ។

[11] ដូចយោងខាងលើ ទំព័រ ៧០-៧១ (ភាសាអង់គ្លេស)។

[12] ដូចយោងខាងលើ ទំព័រ ៧១ (ភាសាអង់គ្លេស)។

[13] ដូចយោងខាងលើ។

៥. ភី ភួន បានបញ្ជាក់បន្ថែមទៀតថា ៖ "គាត់សួរ ខ្ញុំឆ្លើយៗ ដល់ទីបញ្ចប់គាត់អាន ដែលគាត់សួរ ហើយ ខ្ញុំឆ្លើយហ្នឹង គាត់អានហើយ អានចប់ហើយ ឯកភាពគ្នាហើយ បានខ្ញុំផ្តិតមេដៃ"[15]។ គាត់បានបញ្ជាក់ថា មានការថតសំឡេងចំពោះការស្តាប់ចម្លើយទាំងពីរលើកនោះ ប៉ុន្តែគេមិនបានចាក់ខ្សែអាត់នោះឲ្យគាត់ស្តាប់ទេ[16]។ ភី ភួន បានប្រាប់អង្គជំនុំជម្រះសាលាដំបូងថា គាត់ជឿជាក់ថា កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវអ្វីដែលគាត់បានប្រាប់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស[17]។

៦. នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២ មេធាវីការពារក្តីបានសួរសំណួរ ភី ភួន អំពីកាលៈទេសៈជុំវិញការស្តាប់ចម្លើយគាត់ដែលធ្វើឡើងដោយ ក.ស.ច.ស។ ដោយសង្កេតឃើញថា នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីជាភាសាអង់គ្លេស ការស្តាប់ចម្លើយបានចាប់ផ្តើមនៅវេលាម៉ោង ០៩:០០ ព្រឹក ហើយបញ្ចប់នៅវេលាម៉ោង ១១:០០ ល្ងាច[18] ទោះបីជាខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយមានរយៈពេលតែ ១៤នាទី ក៏ដោយ ក៏មេធាវីការពារក្តីបានសួរ ភី ភួន ថាតើការស្តាប់ចម្លើយនេះមានរយៈពេលប៉ុន្មានដែរ[19]។ ភី ភួន បានឆ្លើយតបថា "សម្អាសហ្នឹង គឺពេលព្រឹក ហើយពេលល្ងាច"[20]។ នៅពេលសួរឲ្យពិពណ៌នាថាមានអ្វីកើតឡើងក្នុងអំឡុងពេលនៃការស្តាប់ចម្លើយនោះ ភី ភួន បានឆ្លើយតបថា "គាត់លើកសំណួរ ហើយខ្ញុំឆ្លើយ។ ហើយអាចថា គាត់ថតសំឡេងខ្លះ"[21]។ ភី ភួន បានចង្អុលបង្ហាញថា នៅមុនពេលចាប់ផ្តើមថតសំឡេង ខ្ញុំត្រូវបានគេសួរសំណួរ

---

[14] ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/96.1 ទំព័រ ៧១ (ភាសាអង់គ្លេស)។

[15] ដូចយោងខាងលើ។

[16] ដូចយោងខាងលើ ទំព័រ ៧២។

[17] ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/96.1 ទំព័រ ៧០ (ភាសាអង់គ្លេស)។

[18] ប្រតិចារឹក ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/100.1 ទំព័រ ៣ (ភាសាអង់គ្លេស)។

[19] ដូចយោងខាងលើ។ សំណៅជាភាសាខ្មែរនៃឯកសារ E3/63 ពុំបានបញ្ជាក់ឲ្យបានច្បាស់ឡើយថាតើ ការស្តាប់ចម្លើយនោះបានបញ្ចប់នៅវេលាម៉ោង ១១:០០ ព្រឹក ឬម៉ោង ១១:០០ ល្ងាច។ ថិរវេលាពិតប្រាកដនៃខ្សែអាត់សំឡេងអំពីការស្តាប់ចម្លើយនោះគឺ ១៣នាទី និង១៨វិនាទី។

[20] ដូចយោងខាងលើ ទំព័រ ៤ (ភាសាអង់គ្លេស)។

[21] ដូចយោងខាងលើ ទំព័រ ៤-៥ (ភាសាអង់គ្លេស)។

មួយចំនួន" ប៉ុន្តែ គាត់មិនបានចាំសំណួរដែលគេសួរគាត់នោះឡើយ[22]។ គាត់មិនបានចាំនូវ "ព្រឹត្តការណ៍លម្អិត" នៃការស្តាប់ចម្លើយនោះឡើយ[23]។ ទោះបីជាយ៉ាងណាក៏ដោយ ក្រោយមកទៀត ភី ភួន បានបញ្ជាក់ថា សំណួរ "ចាប់ផ្តើមពីម៉ោង ០៩:០០ ព្រឹក ដល់ម៉ោង ១១:០០ ព្រឹក គិតទៅវាតែពីរម៉ោងទេ។ ចំណុចនេះ ខ្ញុំទទួលស្គាល់អង្គាល់ហ្នឹងគឺថា បានលើកសំណួរហើយ ហើយបានអាន ហើយបានថតសំឡេង ខ្ញុំទទួលស្គាល់នៅចំណុចនេះ"[24]។

៧. ភី ភួន បានស្នើស្តាប់ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយគាត់ ដែលធ្វើឡើងដោយ ក.ស.ច.ស ពីព្រោះគាត់ពុំដឹងថាមានអ្វីនៅក្នុងខ្សែអាត់សំឡេងនោះទេ ហើយគាត់ពុំអាចផ្តល់នូវព័ត៌មានលម្អិតអំពីការស្តាប់ចម្លើយនោះឡើយ[25]។ មេធាវីការពារក្តីក៏បានស្នើឱ្យចាក់ខ្សែអាត់សំឡេងនោះ ដើម្បីឱ្យ ភី ភួន បានស្តាប់[26]។ មេធាវីការពារក្តីបានកត់សម្គាល់ថា នៅពេលស្តាប់ខ្សែអាត់សំឡេង សមាជិកមេធាវីការពារក្តី ដែលនិយាយភាសាខ្មែរបានដឹងថា ការសម្ភាសន៍នោះ "គឺគេបានសរសេរ មិនបានយកមកសួរនិយាយនោះទេ។ នេះហើយគឺអ្វីដែលយើងយល់ ដែលថាវាទៅតាមវិធីមួយ ដែលសាក្សីក៏បាននិយាយនោះ ហើយរីឯការដាក់មកប្រតិចារិកវិញ ហើយបើផ្អែកទៅលើការសង្ខេបនេះ គឺថាសេចក្តីសង្ខេបនេះគឺថា វាមានលក្ខណៈត្រូវគ្នា [ជាមួយនឹង] ប្រតិចារិក"[27]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់មេធាវីការពារក្តី សុំឱ្យចាក់ខ្សែអាត់នោះ ពីព្រោះសំឡេងខ្សែអាត់ និងលក្ខណៈដែលសំណួរគេចោទសួរនោះ គឺមានតែចៅក្រមខ្មែរនៃអង្គជំនុំជម្រះប៉ុណ្ណោះដែលអាចយល់បាន[28]។ មេធាវីការពារក្តីបានស្នើសុំឱ្យកោះហៅអ្នកបកប្រែផ្ទាល់មាត់ដែលបានជួយនៅក្នុងកិច្ចការស្តាប់ចម្លើយដែលបានធ្វើឡើងដោយ ក.ស.ច.ស មកធ្វើសក្ខីកម្មដើម្បី

---

[22] ដូចយោងខាងលើ ទំព័រ ៧ (ភាសាអង់គ្លេស)។

[23] ដូចយោងខាងលើ។

[24] ដូចយោងខាងលើ ទំព័រ ១៣-១៤ (ភាសាអង់គ្លេស)។

[25] ប្រតិចារិក ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/100.1 ទំព័រ ៨ (ភាសាអង់គ្លេស)។

[26] ដូចយោងខាងលើ ទំព័រ ៩ (ភាសាអង់គ្លេស)។

[27] ដូចយោងខាងលើ ទំព័រ ៩-១០ (ភាសាអង់គ្លេស)។

[28] ប្រតិចារិក ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/100.1 ទំព័រ ១១-១៣ (ភាសាអង់គ្លេស)។

បញ្ជាក់ឲ្យបានច្បាស់នូវកាលៈទេសៈនៃការស្តាប់ចម្លើយនោះ[29]។ ដោយយល់ស្របថា បញ្ហានេះគឺជា "បញ្ហាសំខាន់ មិនមែនជាបញ្ហាធម្មតាទេ"[30] អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យដាក់សំណើជាលាយលក្ខណ៍អក្សរ[31]។

៨. នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២ មេធាវីការពារក្តីបាននិយាយជាមួយអ្នកបកប្រែផ្ទាល់មាត់ដែលមានវត្តមានក្នុងអំឡុងការស្តាប់ចម្លើយ ភី ភួន ដែលធ្វើឡើងដោយ ក.ស.ច.ស។ អ្នកបកប្រែផ្ទាល់មាត់នោះ បានបញ្ជាក់ថា អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ពិតជាបានស្តាប់ចម្លើយ ភី ភួន យ៉ាងយូរដែលការស្តាប់ចម្លើយនេះមិនត្រូវបានថតសំឡេងឡើយ។ បន្ទាប់មក អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានរៀបចំសំណួរ និងចម្លើយដែលមានសរសេរជាលាយលក្ខណ៍អក្សរ ដោយផ្អែកទៅលើការស្តាប់ចម្លើយ ដែលពុំមានការថតសំឡេងនេះ ហើយសំណួរ និងចម្លើយទាំងនេះត្រូវបានអានដាក់ឧបករណ៍ថតសំឡេង។ អ្នកបកប្រែផ្ទាល់មាត់នេះបានបញ្ជាក់ថា គាត់បានអានសំណួរឡើង ហើយ ភី ភួន បានអានចម្លើយ។ បន្ទាប់មក កំណត់ហេតុនៃការស្តាប់ចម្លើយត្រូវបានរៀបចំឡើង ដោយផ្អែកលើសំណួរ និងចម្លើយដែលត្រូវបានថតសំឡេងទាំងនេះ។

## II. ច្បាប់

៩. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ("រដ្ឋធម្មនុញ្ញ") ចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយ ទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។

១០. មាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា អំណាចតុលាការ "ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ"។

---

[29] ដូចយោងខាងលើ ទំព័រ ៨៣-៨៤ (ភាសាអង់គ្លេស)។

[30] ដូចយោងខាងលើ ទំព័រ ៨៦ (ភាសាអង់គ្លេស)។

[31] ដូចយោងខាងលើ។

១១. មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”) ឆ្នាំ១៩៦៦ (ដែលដាក់ បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ កិច្ចព្រមព្រៀង[32] និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក[33]) ចែងជាអន្តរជាតិ ទទួលស្គាល់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ដែលត្រូវបាន ធានាដល់ជនជាប់ចោទ នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ។ មាត្រា ១៤(១) ចែងថា ៖ “ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្ដីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្ដីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន...”។ មាត្រា ១៤(៣) ធានាថា ៖

> ក្នុងការសម្រេចសេចក្ដីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូប មានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖
>
> ... (ឃ) ត្រូវមានការសួរចម្លើយ ឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សី ដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក...[34]។

១២. មាត្រា ៣៥ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែលដាក់បញ្ចូលមាត្រា ១៤ នៃ ICCPR ចែងថា ៖

> នៅក្នុងការចោទប្រកាន់មកលើខ្លួន *ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា...*

---

[32] កិច្ចព្រមព្រៀង មាត្រា ១២(២) ចែងថា អង្គជំនុំជម្រះវិសាមញ្ញ “ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃ [ICCPR] ឆ្នាំ១៩៦៦ ដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ”។

[33] ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣ថ្មី ចែងថា ៖ “អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ... [និង] ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃ [ICCPR]” (សេចក្ដីបញ្ជាក់បន្ថែម)។

[34] សេចក្ដីបញ្ជាក់បន្ថែម។

*ង. ពិនិត្យភ័ស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភ័ស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នានឹងភ័ស្តុតាងដាក់បន្ទុកដែរ*[35]។

១៣. វិធាន ៩៣(១) ដែលចម្លងតាមមាត្រា ៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("CPC")[36] ចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធថា ៖ "ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា"។ វិធាន ៩៣(២)(ខ) ចែងថា ការស៊ើបសួរនេះអាចរួមមានការស្តាប់ចម្លើយសាក្សី។

១៤. វិធាន ២១(១) ចែងថា ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងវិធាន ៩៣ ជាធរមាន "ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់... ជនជាប់ចោទ... និងដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង"[37]។ ក្នុងបរិបទនេះ វិធាន ២១(១)(ក) ចែងថា "ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។

## III. **ទន្និករណ៍**

១៥. ដើម្បីឲ្យដំណើរការជំនុំជម្រះក្តីមានភាពយុត្តិធម៌ និងតម្លាភាព អង្គជំនុំជម្រះសាលាដំបូងគួរប្រើប្រាស់អំណាចស៊ើបអង្កេតរបស់ខ្លួន និងកោះហៅអ្នកបកប្រែផ្ទាល់មាត់ ដើម្បីបង្ហាញភ័ស្តុតាងទាក់ទងនឹងការស្តាប់ចម្លើយ ភី ភួន លើកទីពីរដែលធ្វើឡើងដោយក.ស.ច.ស។ ព័ត៌មានដែលទទួលបានដោយ

---

[35] សេចក្តីបញ្ជាក់បន្ថែម។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៣៩ ចែងថា ៖ "ប្រសិនបើយល់ឃើញថា ការស្រាវជ្រាវថ្មីជាការចាំបាច់ តុលាការអាចបង្គាប់តាមសាលក្រមឲ្យធ្វើការស៊ើបសួរបន្ថែម...។ នៅក្នុងលក្ខខណ្ឌដូចគ្នានឹងចៅក្រមស៊ើបសួរ ចៅក្រម [ដែលត្រូវបានចាត់តាំង] នេះ អាច... ស្តាប់ចម្លើយសាក្សី"។

[37] សេចក្តីបញ្ជាក់បន្ថែម។

មេធាវីការពារក្តីបានបង្ហាញថា អ្នកស៊ើបអង្កេតរបស់ក.ស.ច.ស បង្កើតឲ្យមានការចាប់អារម្មណ៍ដោយចេតនាថា កំណត់ហេតុស្តាប់ចម្លើយសាក្សីជាសង្ខេប គឺជាការឆ្លុះបញ្ចាំងពិតប្រាកដអំពីការស្តាប់ចម្លើយសាក្សីជាមួយអ្នកស៊ើបអង្កេតក.ស.ច.ស[38]។ ការធ្វើដូច្នេះត្រូវចាត់ទុកថាជាការលេងផ្តិនផ្តែក។ ការសន្ទនាក្រៅផ្លូវការរបស់មេធាវីការពារក្តីជាមួយនឹងអ្នកបកប្រែផ្ទាល់មាត់បានបង្ហាញថា ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សី ត្រូវបានធ្វើឡើងដោយមានការរៀបចំ៖ ការស្តាប់ចម្លើយដែលពុំបានថតសំឡេងបានកើតឡើងរួចទៅហើយ។ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានរៀបចំសំណួរ និងចម្លើយ ដោយផ្អែកតាមការស្តាប់ចម្លើយដែលពុំបានថតសំឡេង ហើយបន្ទាប់មកសំណួរ និងចម្លើយទាំងនោះ ត្រូវបានអាន និងថតដាក់ក្នុងឧបករណ៍ថតសំឡេង។ សំណួរ និងចម្លើយទាំងនោះ មិនស៊ីគ្នានឹងការចងចាំអំពីព័ត៌មាននៃព្រឹត្តិការណ៍នានារបស់ ភី ភួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទេ។ ទាំងសក្ខីកម្មរបស់ ភី ភួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទាំងកំណត់ហេតុស្តាប់ចម្លើយសាក្សី និងទាំងខ្សែអាត់សំឡេង មិនបានផ្តល់ការរៀបរាប់ត្រឹមត្រូវចំពោះការស្តាប់ចម្លើយ ភី ភួន លើកទីពីរដែលធ្វើឡើយដោយមន្ត្រីស៊ើបអង្កេតរបស់ ក.ស.ច.ស នោះទេ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី មិនបានបង្ហាញថា ភី ភួន ត្រូវបានសួរសំណួរ មុនពេលចាប់ផ្តើមការថតខ្សែអាត់សំឡេង ឬមិនបានបង្ហាញថា ខ្សែអាត់សំឡេងស៊ីគ្នានឹងថិរវេលានៃការស្តាប់ចម្លើយទេ។ អនុលោមតាមវិធាន៩៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង មានអំណាចធ្វើការស៊ើបអង្កេតបន្ថែមនៅពេលចាំបាច់ ដោយរួមបញ្ចូលទាំងការស្តាប់ចម្លើយសាក្សីផងដែរ[39]។ ពេលវេលាដែលចាំបាច់សម្រាប់ឲ្យអង្គជំនុំជម្រះធ្វើដូច្នេះ បានមកដល់ហើយ។

១៦. កាលៈទេសៈនានាដែលនាំឲ្យមានសំណើសុំនេះ បានបង្ហាញយ៉ាងច្បាស់អំពីតម្រូវការចាំបាច់សម្រាប់ការរៀបរាប់ត្រឹមត្រូវ នៃការស្តាប់ចម្លើយសាក្សី ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស និងខ្សែអាត់សំឡេងពេញលេញទាំងស្រុងនៃការស្តាប់ចម្លើយទាំងនោះ។ ភី ភួន គឺជាសាក្សីសំខាន់មួយរូបនៅក្នុងសំណុំរឿង០០២/០១ ដូចបានបង្ហាញតាមរយៈអង្គហេតុដែលថា គាត់

---

[38] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ E3/63។

[39] វិធាន៩៣ នៃវិធានផ្ទៃក្នុង ស្របគ្នានឹងមាត្រា ៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

បានផ្តល់សក្ខីកម្មរយៈពេលប្រាំថ្ងៃចាប់ពីប្រធានបទស្តីពីការជម្លៀសចេញពីភ្នំពេញ រហូតដល់ប្រធានបទស្តីពីរចនាសម្ព័ន្ធ និងតួនាទីរបស់ក្រសួងការបរទេស[40]។ នៅពេលមេធាវីការពារក្តីសួរដេញដោល ភី ភួន គាត់មិនអាចចាំសំណួរ ដែលគេសួរគាត់ក្នុងអំឡុងពេលនៃការស្តាប់ចម្លើយសាក្សី ដែលធ្វើឡើងដោយក.ស.ច.ស កាលពីឆ្នាំ២០០៨ នោះទេ[41]។ គាត់បានផ្តល់នូវចម្លើយមិនស៊ីសង្វាក់គ្នា ទាក់ទិននឹងថិរវេលានៃការស្តាប់ចម្លើយនេះ[42] ដូចគ្នានឹងចម្លើយ ដែលគាត់បានផ្តល់ទាក់ទិននឹងព្រឹត្តិការណ៍សំខាន់ផ្សេងៗទៀត ដូចជាតួនាទីរបស់គាត់នៅក្រសួងការបរទេសដែរ។ វាក៏មានភាពមិនស៊ីសង្វាក់គ្នាយ៉ាងច្បាស់រវាងការស្តាប់ចម្លើយ ភី ភួន លើកទីមួយ និងការស្តាប់ចម្លើយ ភី ភួន លើកទីពីរ ដែលធ្វើឡើងដោយ ក.ស.ច.ស។ នៅក្នុងការស្តាប់ចម្លើយលើកទីមួយ ភី ភួន បានលើកឡើងថា លោក អៀង សារី មិនដែលមានកិច្ចប្រជុំណាមួយជាមួយបុគ្គលិក ដើម្បីពិភាក្សាអំពីការបាត់ខ្លួននៅក្រសួងការបរទេសទេ[43]។ ភី ភួន ក៏បានលើកឡើងថា ខ្លួនគាត់ផ្ទាល់

---

[40] *សូមមើល* ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/96.1។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/97.1។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/98.1។ ប្រតិចារឹក ថ្ងៃទី ៣១ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/99.1។ ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/100.1។ ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/101.1។

[41] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/100.1 ទំព័រ៧។

[42] *ដូចខាងលើ* ទំព័រ ៤, ១៣។ *សូមមើលដូចខាងលើផងដែរ* សារតារ កថាខណ្ឌ៦។

[43] *សូមមើល* ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/99.1 ទំព័រ៩០-៩៣ (គូសបញ្ជាក់បន្ថែម)៖

> [ភី ភួន]៖ ... *ខ្ញុំអត់បានធ្វើការខាងសន្តិសុខទេ* ... [ភី ភួន]៖ ផ្នែកសន្តិសុខបានជម្រាបហើយថា ខ្ញុំអត់បានធ្វើទេ ការងារសន្តិសុខហ្នឹង។ គឺការងារខ្ញុំ គឺជាការងារខាងរដ្ឋបាល ...។ [លោក KARNAVAS] សំណួរ៖ ដូច្នេះ សួរ ហុង មិនដែលគ្រប់គ្រង ឬផ្តល់ការងារឱ្យលោកធ្វើការខាងផ្នែកសន្តិសុខមែនទេ ឬយ៉ាងណា? [ភី ភួន] ឆ្លើយ៖ *ដូចគាត់អត់មានផ្តល់បញ្ហាការងារសន្តិសុខអីទេ ថាអត់ៗទេ។* [លោក KARNAVAS] សំណួរ៖ មានន័យថា សួរ ហុង មិនដែលបាន -- មិនដែលចាត់តាំងការងារផ្នែកខាងសន្តិសុខនេះឱ្យលោកធ្វើទេ។ ខ្ញុំចង់សង្កត់ធ្ងន់ឡើងវិញ ដើម្បីឱ្យខ្ញុំយល់ច្បាស់អំពីចម្លើយនិងជំហររបស់លោក តើអីចឹងមែនទេ? [ភី ភួន] ឆ្លើយ៖ បាទដូចខ្ញុំបានបញ្ជាក់អំមិញអីចឹងបាទ។

*ប្រៀបធៀប* ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ ឯកសារE1/100.1 ទំព័រ៥៣ (គូសបញ្ជាក់បន្ថែម)៖

> [លោក KARNAVAS] សំណួរ៖ លោក សាក្សី នៅទីនេះយើងមាន -- យើងឃើញថា មានមេរបស់លោកគឺ សួរ ហុង ដែលនិយាយថាលោកមានមុខងារក្នុងចំណោមហ្នឹងគឺមានមុខងារផ្នែកសន្តិសុខដែរ។ តើលោកនៅតែរក្សាសម្តី

មិនបានដឹងអំពីការបាត់ខ្លួនរបស់បុគ្គលិកនៅក្រសួងការបរទេសទេ[44]។ គាត់មិនបានលើកឡើងថា លោក អៀង សារី មាន ឬបានអានចម្លើយសារភាពទេ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការស្ដាប់ចម្លើយលើកទីពីរ ភី ភួន បានលើកឡើងថា គាត់បានប្រាប់ថា គាត់បានដឹងអំពីការចាប់ខ្លួនបុគ្គលិកពីក្រសួងការបរទេស ហើយលោក អៀង សារី បានប្រាប់គាត់អំពីការទទួលបានចម្លើយសារភាព[45]។ ដោយសារតែការស្ដាប់ចម្លើយពិតប្រាកដ (ដែលខុសគ្នាពីការអានសំណួរ និងចម្លើយដែលបានរៀបចំទុកជាមុន) មិនត្រូវបានថតទុកក្នុងខ្សែអាត់សំឡេង ដូចនេះវាមិនដឹងថាតើហេតុអ្វីបានជាមានភាពខុសគ្នាទាំងនេះ ឬវាជាភាពខុសគ្នា ដែលអ្នកស៊ើបអង្កេត ជាអ្នកបង្កឲ្យកើតមានឡើង ឬយ៉ាងណានោះទេ។ ឧទាហរណ៍ ប្រសិនបើមិនមានភ័ស្ដុតាងពីអ្នកបកប្រែផ្ទាល់មាត់ យើងមិនដឹងថាតើ ភី ភួន ទទួលរងឥទ្ធិពល ឬត្រូវបានគេអូសទាញឲ្យឆ្លើយចម្លើយដែលមិនស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលគាត់ឆ្លើយពីមុនក្រោមការស្បថ (ឬចម្លើយផ្សេងទៀតដែលគាត់បានធ្វើក្នុងអំឡុងពេលការស្ដាប់ចម្លើយលើកទីពីររបស់ក.ស.ច.ស) នោះទេ។

១៧. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមិនធ្វើការស៊ើបអង្កេតបន្ថែម មេធាវីការពារក្ដីនឹងបាត់បង់ឱកាសវាយតម្លៃភ័ស្ដុតាងនេះ តាមរយៈការពិនិត្យមើលវិធីដែលការស្ដាប់ចម្លើយលើកទីពីររបស់ ភី ភួន ត្រូវបានធ្វើឡើង។ មេធាវីការពារក្ដីមានសិទ្ធិអនុវត្តដោយផ្អែកតាមរដ្ឋធម្មនុញ្ញ[46] ច្បាប់ និងនីតិវិធីរបស់អ.វ.ត.ក[47] និងកតិកាសញ្ញាICCPR[48]។ មេធាវីការពារក្ដីមិនអាចលើកភ័ស្ដុតាង

---

របស់លោកដែរឬទេថា លោកអត់មានជាប់ពាក់ព័ន្ធធ្វើការងារសន្តិសុខទេ នៅពេលដែលលោកនៅក្រសួងការបរទេសនោះ? [ភី ភួន] ឆ្លើយៈ ខ្ញុំចំណុចនេះ ខ្ញុំសូមបញ្ជាក់ឡើងវិញគឺថា ក្នុងក្រសួងនេះ ទីមួយ អ៊ំ អៀង សារី ហ្នឹង ហើយទីពីរ បង សួរ ហុង ហ្នឹងហើយ ហើយនឹងទីបីហ្នឹង គឺថាខ្ញុំនឹងហើយ។ ហើយកិច្ចការសន្តិសុខគឺថាបីនាក់ហ្នឹងទទួលខុសត្រូវដូចៗគ្នាហ្នឹង។ ... ហើយខ្ញុំនៅហ្នឹងខាងផ្នែករដ្ឋបាលហ្នឹង ខ្ញុំមើលសន្តិសុខដែរ។

[44] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារE3/24 ទំព័រ៨-៩។

[45] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារE3/63 ទំព័រ៤។

[46] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ចែងថាៈ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុង ... កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស [ដែលមានរួមបញ្ចូលកតិកាសញ្ញាICCPR]"។

[47] មាត្រា៣៣(ថ្មី), ៣៥(ថ្មី) នៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក។ មាត្រា ១២(២) នៃកិច្ចព្រមព្រៀង។ វិធាន២១(១)(ក) នៃវិធានផ្ទៃក្នុង ដែលតម្រូវឲ្យ "ដំណើរការនីតិវិធី ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។

ផ្សេងទៀត ដើម្បីកែតម្រូវការខូចប្រយោជន៍ ដែលកើតចេញមកពីភាពមិនប្រក្រតីនៅក្នុងការស្តាប់ចម្លើយ ភី ភួន លើកទីពីរដែលធ្វើឡើងដោយក.ស.ច.សទេ[49]។ ប្រសិនបើកំហុសដែលមាននៅក្នុងដំណើរការស៊ើបអង្កេត ត្រូវបានដោះស្រាយដោយដីកាដំណោះស្រាយ នោះលោកប្រធាន និល ណុល ប្រហែលមិនអាចរកឃើញថា ករណីនេះ គឺជា "បញ្ហាសំខាន់ មិនមែនជាបញ្ហាធម្មតាទេ" នោះទេ[50]។ កង្វះការស៊ើបអង្កេតលើបញ្ហានេះ នឹងនាំឲ្យដំណើរការនីតិវិធីតុលាការមានកំហុសឆ្គង នៅពេលដែលភាពមិនប្រក្រតី និងការប្រព្រឹត្តិដោយចេតនា ឬអចេតនា ត្រូវបានកប់ចោល និងមើលរំលង (ឬក៏មិនត្រូវបានដោះស្រាយដោយចេតនា) ទោះបីជានៅពេលជាមួយគ្នានោះ ដំណើរការស្វែងរកការពិត កំពុងត្រូវបានអះអាងថាកំពុងបន្តទៅមុខក្តី។ សក្ខីកម្មរបស់អ្នកបកប្រែផ្ទាល់មាត់ គឺចាំបាច់ ដោយសារតែសក្ខីកម្មនេះ នឹងកំណត់អំពីតម្លៃនៃការថ្លឹងថ្លែង (ប្រសិនបើមាន) ដែលអាចផ្តល់ឲ្យដល់ចម្លើយដែលមាននៅក្នុងការស្តាប់ចម្លើយ ភី ភួន លើកទីពីរ។ វានឹងជួយអង្គជំនុំជម្រះសាលាដំបូងបន្ថែមទៀត ក្នុងការវាយតម្លៃលើភាពអាចជឿជាក់ចំពោះសាក្សី ភី ភួន និងការថ្លឹងថ្លែងសក្ខីកម្មដែលគាត់ផ្តល់នៅក្នុងតុលាការ។ មេធាវីការពារក្តី មិនបានស្នើសុំការស៊ើបអង្កេត "ដែលមិនមានដែនកំណត់" ពាក់ព័ន្ធនឹងបុគ្គលអនាមិកនោះទេ។ សំណើសុំនេះ កំណត់ត្រឹមតែបញ្ហាយ៉ាងច្បាស់លាស់ និងជាក់លាក់ ដែលតម្រូវឲ្យមានសក្ខីកម្មពីបុគ្គលដែលកំណត់អត្តសញ្ញាណ ដែលបុគ្គលនោះមានវត្តមានក្នុងអំឡុងពេលសម្ភាសន៍ ដែលមានវិវាទនេះ។ បន្ថែមពីលើនេះ ដោយសារតែសំណើសុំកំណត់ចង្អៀតត្រឹមស្ថានភាពនៃការស្តាប់ចម្លើយ ភី ភួន លើកទីពីរ ដូចនេះសក្ខីកម្មរបស់អ្នកបកប្រែផ្ទាល់មាត់ នឹងមិនអូសបន្លាយដំណើរការនីតិវិធី ហួសពីការចាំបាច់នោះទេ។

---

[48] មាត្រា ១៤(៣) នៃកតិកាសញ្ញា ICCPR។

[49] *ប្រៀបធៀប* សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E53/1, E82, E88 និងE92) ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារE116 កថាខណ្ឌ ១៩៖ "អង្គជំនុំជម្រះយល់ឃើញថា វាជាការជំនុំជម្រះក្តីមួយប្រកបដោយភាពយុត្តិធម៌និងជាសាធារណៈ ព្រោះជនជាប់ចោទមានឱកាសក្នុងការស្នើសុំឲ្យអង្គជំនុំជម្រះកោះហៅសាក្សីដោះបន្ទុក បង្ហាញភ័ស្តុតាងជាឯកសារ ឬភ័ស្តុតាងផ្សេងទៀតដែលចាំបាច់ដើម្បីបញ្ជាក់ការពិតសួរសំណួរទៅកាន់សាក្សីរបស់ភាគីម្ខាងទៀត និងតតាំងជាមួយនឹងភ័ស្តុតាងនានា ព្រមទាំងការចោទប្រកាន់ផ្សេងៗមកលើគាត់ ដែលជាការជួសជុលភាពខ្វះចន្លោះនៃកិច្ចស៊ើបសួរដែលត្រូវបានចោទប្រកាន់មកទល់នឹងពេលនេះ"។

[50] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ ឯកសារE1/100.1 ទំព័រ៨៦។

១៨. ករណីនេះ មិនមែនជាលើកដំបូងដែលភាពមិនប្រក្រតី បានកើតមាននៅពេលស្ដាប់ចម្លើយសាក្សីនោះទេ។ ពីមុនមក មេធាវីការពារក្ដីបានលើកឡើងនូវការព្រួយបារម្ភអំពីភាពខុសគ្នាយ៉ាងច្បាស់រវាងចម្លើយសាក្សីមួយចំនួន ដែលធ្វើឡើងដោយក.ស.ច.ស និងខ្សែអាត់សំឡេង[51]។ នៅក្នុងករណីមួយចំនួន មានតែកំណត់ហេតុស្ដាប់ចម្លើយសាក្សី ប៉ុន្តែមិនមានខ្សែអាត់សំឡេងនោះទេ[52]។ នៅក្នុងករណីផ្សេងទៀត ខ្សែអាត់សំឡេងបានបង្ហាញច្បាស់ថា មានកិច្ចសម្ភាសន៍មុនជាមួយសាក្សីដែលមិនមានថតសំឡេង[53]។ ឧទាហរណ៍ នៅខែមិថុនា លោក អឿន តាន បានផ្ដល់សក្ខីកម្មថា អ្នកស៊ើបអង្កេតរបស់ក.ស.ច.ស បានស្ដាប់ចម្លើយគាត់ ហើយការស្ដាប់ចម្លើយនោះ ត្រូវបានថតសំឡេង[54]។ បន្ទាប់មក គាត់បានបង្ហាញថា មួយថ្ងៃមុនថ្ងៃស្ដាប់ចម្លើយ អ្នកស៊ើបអង្កេតបានសួរសំណួរគាត់ពេញមួយថ្ងៃដោយមិនបានថតសំឡេងនូវសំណួរ និងចម្លើយនោះទេ[55]។ កំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលធ្វើឡើងដោយ ក.ស.ច.ស មិនបានលើកឡើងអំពីការស្ដាប់ចម្លើយមុនដំបូងនោះទេ។ ក.ស.ព បានទទួលស្គាល់អំពីអត្ថិភាពនៃការសង្ស័យនេះ ថាតើ “អ្វីដែលដាក់នៅក្នុងកំណត់ហេតុ និងកិច្ចសម្ភាសន៍អ្វីបានធ្វើឡើង”[56]។ លោក Andrew Cayley សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងនូវការព្រួយបារម្ភស្រដៀងគ្នានេះដែរ ទាក់ទិននឹង “ភាពមិនស្របគ្នា ឬចន្លោះប្រហោងមួយចំនួន” នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលធ្វើឡើងដោយក.ស.ច.ស

---

[51] *សូមមើល* លិខិតពីក្រុមមេធាវីការពារក្ដី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា “ការជំទាស់ទៅនឹងចម្លើយសាក្សី” ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារE96/7/1។ សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្ដាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារE142។

[52] ឧទាហរណ៍ ឯកសារ D199/15 ដែលតាមរយៈឯកសារនេះបង្ហាញឱ្យឃើញថា យ៉ាងហោចណាស់ចម្លើយសាក្សីចំនួន១២ដែលពុំមានថតសំឡេង មាននៅក្នុងសំណុំរឿង។

[53] សូមមើល ឯកសារ D125/92R ត្រង់ចំណុចម៉ោង 00:0៧:៥៨-00:0៨:១០។

[54] ប្រតិចារឹក ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E1/87.1 ទំព័រ ៤៧ (ភាសាអង់គ្លេស)។

[55] ដូចយោងខាងលើ ទំព័រ ៤៧-៤៨ (ភាសាអង់គ្លេស)។

[56] ដូចយោងខាងលើ ទំព័រ ៥៣ (ភាសាអង់គ្លេស)។

និងខ្សែអាត់សំឡេងនៅក្នុងសំណុំរឿង០០៣ និង០០៤[57]។ អ្នកស៊ើបអង្កេតអន្តរជាតិរបស់ ក.ស.ច.ស ដែលបានស្តាប់ចម្លើយ ភី ភួន លើកទីពីរ ត្រូវបានមេធាវីការពារក្តី នួន ជា លើកឡើងនៅក្នុងសារណាថាមាន៖ **ក.** ការស្តាប់ចម្លើយសាក្សីមួយចំនួនដែលធ្វើឡើងដោយក.ស.ច.ស មិនមានថតសំឡេងក្នុងខ្សែអាត់។ **ខ.** បានបញ្ចូលគ្នានូវការស្តាប់ចម្លើយសាក្សីជាច្រើនទៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីតែមួយ។ និង **គ.** បញ្ចូលចម្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមិនមាននៅក្នុងខ្សែអាត់សំឡេងនៃបទសម្ភាសន៍ទាំងនោះ[58]។

១៩. លទ្ធភាពដែលសំណួរ និងចម្លើយនៅក្នុងកិច្ចសម្ភាសន៍ ភី ភួន លើកទីពីរ ផ្អែកលើការសម្ភាសន៍ពីមុនដែលមិនមានថតសំឡេង បានធ្វើឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំង អំពីភាពអាចជឿជាក់ទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ ភី ភួន និងតាមពិត គឺ *គ្រប់*កំណត់ហេតុស្តាប់ចម្លើយទាំងអស់តែម្តង។ ក.ស.ព បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងផ្អែកទាំងស្រុងលើកំណត់ហេតុស្តាប់ចម្លើយសាក្សីប្រហែល១៤០០ ជាជាងការស្តាប់សក្ខីកម្មសួរដេញដោល*ផ្ទាល់មាត់*[59] ហើយអង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកកំណត់ហេតុស្តាប់ចម្លើយរបស់ក.ស.ច.ស ថាជាការឆ្លុះបញ្ចាំង

[57] ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដល់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយមានឧបសម្ព័ន្ធ ក សម្ងាត់បំផុត ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E127 កថាខណ្ឌ ១៤។

[58] សូមមើលសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០១ ឯកសារ E142 កថាខណ្ឌ ៥-៧។ អ្នកស៊ើបអង្កេតរូបនេះលែងបម្រើការឱ្យ អ.វ.ត.ក ទៀតហើយ។

[59] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E96។ សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកចម្លើយសាក្សី ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E208។ សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកចម្លើយសាក្សីនានាដែលទាក់ទងនឹងដំណាក់កាលទី២ នៃការជម្លៀសប្រជាជន និងបញ្ហាភស្តុតាងផ្សេងទៀត ជាមួយឧបសម្ព័ន្ធសម្ងាត់ I, II, III, និងឧបសម្ព័ន្ធ IV សាធារណៈ ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E208/2។ សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុ ជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ពី១-១៦ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E96/8។

“ស្មោះត្រង់ និងពិតប្រាកដ” នៃការស្តាប់ចម្លើយពិតប្រាកដ[60]។ យោងតាមការព្រួយបារម្ភដែលបានលើកឡើងរួចហើយ អំពីអ្នកស៊ើបអង្កេតអន្តរជាតិរបស់ក.ស.ច.ស ដែលធ្វើការស្តាប់ចម្លើយសាក្សីភាពផ្ទុយគ្នានៅក្នុងសក្ខីកម្ម និងកំណត់ហេតុស្តាប់ចម្លើយរបស់ ភី ភួន នាំឲ្យមានតម្រូវការយ៉ាងពិតប្រាកដនូវការស៊ើបអង្កេតបន្ថែមដោយអង្គជំនុំជម្រះសាលាដំបូង។

២០. រដ្ឋធម្មនុញ្ញ[61] កិច្ចព្រមព្រៀង[62] ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក[63] វិធានផ្ទៃក្នុង[64] និងកតិកាសញ្ញា ICCPR[65] តម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងធានាថា លោក អៀង សារី ទទួលបានការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌។ លោក អៀង សារី មិនអាចទទួលបានការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌នោះទេ ប្រសិនបើគាត់មិនត្រូវបានអនុញ្ញាតឲ្យពិនិត្យមើលឲ្យបានត្រឹមត្រូវលើភ័ស្តុតាង

---

[60] សូមមើល ឧទាហរណ៍ ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E1/23.1 ទំព័រ ២១-២៤ ត្រង់ចំណុចដែលចៅក្រម Lavergne សួរលោក ឡុង នរិន្ទ អំពីកំណត់ហេតុនៃការស្តាប់ចម្លើយរបស់គាត់ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស។ កំណត់ហេតុនៃការស្តាប់ចម្លើយសង្ខេបប្រតិចារឹកនៃការស្តាប់ចម្លើយចំនួន ៩៨ទំព័រ។ លោក ឡុង នរិន្ទ បានចង្អុលបង្ហាញថា គាត់ទទួលស្គាល់ហត្ថលេខា និងស្នាមមេដៃរបស់គាត់នៅលើកំណត់ហេតុនោះ ប៉ុន្តែគាត់មិនបានចាំថាតើអ្នកស៊ើបអង្កេតបានអានកំណត់ហេតុនោះឮៗឲ្យគាត់ស្តាប់ ឬយ៉ាងណានោះឡើយ។ ចៅក្រម Lavergne បានសួរលោក ឡុង នរិន្ទ ថាតើចម្លើយ នៅក្នុងកំណត់ហេតុនោះ “វាស៊ីគ្នានឹងអ្វីដែលលោកបានជម្រាបជូនទៅដល់អ្នកស៊ើបអង្កេតដែរឬទេ”។ ដូចយោងខាងលើ ទំព័រ ២៣ (ភាសាអង់គ្លេស) លោក ឡុង នរិន្ទ បានឆ្លើយថា គាត់ពុំបានចាំថា “កំណត់ហេតុនេះស៊ើបអង្កេតពីអង្កាល់ណាឡើយ”។ ដូចយោងខាងលើ ចៅក្រម Lavergne បានបញ្ជាក់ថា “សំណួរហ្នឹងមិនមែនសួរថា តើលោកដឹង ចង់ដឹងថាឲ្យលោកចាំថា ពេលណាដែលលោកផ្តល់ចម្លើយនេះទេ។ សំណួរគឺចង់ដឹងថា តើអ្វីដែលសរសេរនៅក្នុងកំណត់ហេតុហ្នឹង ដូចនឹងអ្វីដែលលោកបានរៀបរាប់ប្រាប់ អ្នកស៊ើបអង្កេតដែរឬអត់?” ដូចយោងខាងលើ លោក ឡុង នរិន្ទ បានឆ្លើយតបថា “គ្រប់យ៉ាងមាននៅក្នុងហ្នឹងអស់ហើយ” ប៉ុន្តែគាត់ “ពិតជាចាំមិនបានថា [គាត់] បានផ្តល់ចម្លើយទៅឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតនៅពេលណាឡើយ។ ខ្ញុំបាត់បង់ការចងចាំ ច្រើនណាស់”។ ដូចយោងខាងលើ ចៅក្រម Lavergne បានថ្លែងអំណរគុណដល់សាក្សី ហើយពុំមានសំណួរអ្វីបន្ថែមទៀតឡើយ។ ដូចយោងខាងលើ ទំព័រ ២៤(ភាសាអង់គ្លេស)។

[61] មាត្រា ៣១ និង ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញ ។

[62] មាត្រា ១២(២) នៃកិច្ចព្រមព្រៀង។

[63] មាត្រា ៣៣ថ្មី និង ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[64] វិធាន ២១ នៃវិធានផ្ទៃក្នុង។

[65] មាត្រា ១៤(១) ១៤(៣) នៃកតិកាសញ្ញាICCPR (ដែលត្រូវបានដាក់បញ្ចូលទៅក្នុងនីតិវិធី និងច្បាប់ស្តីពីការបង្កើតអ.វ.ត.ក តាមរយៈមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ១២ នៃកិច្ចព្រមព្រៀង)។

ប្រឆាំងនឹងរូបគាត់។ ដូចដែលបានទទួលស្គាល់ដោយប្រធាន និល ណុល ភាពមិនប្រក្រតីនៅក្នុងការស្តាប់ចម្លើយ ភី ភួន លើកទីពីរ ដែលធ្វើឡើងដោយក.ស.ច.ស បានបង្ហាញនូវ "បញ្ហាសំខាន់មិនមែនជាបញ្ហាធម្មតាទេ"[66]។ ភាពមិនប្រក្រតី គឺជាចំណុចសំខាន់នៃលទ្ធភាពរបស់លោក អៀង សារី ក្នុងការពិនិត្យ និងតវ៉ាភាពអាចជឿទុកចិត្តរបស់ ភី ភួន ដែលការថ្លឹងថ្លែង គួរតែស្របទៅនឹងសក្ខីកម្មរបស់គាត់ និងលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីបញ្ជាក់ការពិត។ ដោយពិចារណាដល់ភាពសំខាន់របស់ ភី ភួន នៅក្នុងរឿងក្តីនេះ និងភាពអាចជឿទុកចិត្តដែលអង្គជំនុំជម្រះសាលាដំបូង និងក.ស.ពមានលើកំណត់ហេតុស្តាប់ចម្លើយសាក្សី វាសំខាន់ណាស់ដែលថាស្ថានភាពនៃការស្តាប់ចម្លើយ ភី ភួន ដែលធ្វើឡើងដោយក.ស.ច.ស ត្រូវតែបំភ្លឺឲ្យបានច្បាស់។ ដូចដែលលោកប្រធាន និល ណុល បានលើកឡើង អ.វ.ត.ក គឺជា "អង្គជំនុំជម្រះវិសាមញ្ញ"[67] ហេតុដូចនេះ បទដ្ឋាន និងការធានាដែលមានចែងនៅក្នុងច្បាប់អ.វ.ត.ក និងនីតិវិធី ត្រូវតែពិចារណាតាមបទដ្ឋានអន្តរជាតិ[68]។ លោកប្រធាន និល ណុល ក៏បានលើកឡើងថា អ.វ.ត.ក ប្រកាន់ភ្ជាប់និងផ្អែកជាគោលលើវិធានផ្ទៃក្នុង[69]។ វិធានទាំងនេះ បានចែងយ៉ាងច្បាស់អំពីដំណោះស្រាយមួយ គឺនៅត្រង់វិធាន៩៣ នៃវិធានផ្ទៃក្នុង។ អនុលោមតាមវិធាននេះ អង្គជំនុំជម្រះសាលាដំបូង គួរប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីកោះហៅអ្នកបកប្រែផ្ទាល់មាត់ឲ្យមកផ្តល់ភ័ស្តុតាង។ ទោះបីជាការស៊ើបអង្កេតបន្ថែម អាចលេចចេញនូវបញ្ហាមិនសមទំនងអំពីសុចរិតភាព នៃដំណើរការនីតិវិធីស៊ើបអង្កេតរបស់ក.ស.ច.សក៏ដោយ ក៏ចំណាត់ការដាច់ខាតរបស់អង្គជំនុំជម្រះសាលាដំបូង នឹងបង្ហាញអំពីការតាំងចិត្តក្នុងការធានាអំពីដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងតម្លាភាពសម្រាប់ភាគីទាំងអស់។ ការខកខានមិនបានចាត់វិធានការភ្លាមៗលើបញ្ហានេះ - នៅពេលមានសាក្សីដែលអាចផ្តល់សក្ខីកម្ម - នឹងជាសញ្ញាដល់សាធារណជន ភាគីនានា និងអង្គភាពរបស់អ.វ.ត.កផ្សេងៗទៀត

---

[66] ប្រតិចារឹក ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/100.1 ទំព័រ ៨ (ភាសាអង់គ្លេស)។

[67] ដូចយោងខាងលើ ទំព័រ ៨៦ (ភាសាអង់គ្លេស)។

[68] អ.វ.ត.ក បានទទួលស្គាល់ចំណុចនេះ ដោយដាក់បញ្ចូលបទដ្ឋានច្បាប់អន្តរជាតិ ជាពិសេស ICCPR ទៅក្នុងកិច្ចព្រមព្រៀងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាននានា។ មាត្រា ១៤(៣) នៃ ICCPR ធានានូវសិទ្ធិរបស់ជនជាប់ចោទក្នុងការពិនិត្យភ័ស្តុតាង ប្រឆាំងខ្លួន។

[69] ប្រតិចារឹក ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/100.1 ទំព័រ ៨៦ (ភាសាអង់គ្លេស)។

ថា អ.វ.ត.ក មិនមែនជាតុលាការគំរូទេ ប៉ុន្តែគ្រាន់តែជាតុលាការមួយ មានឆន្ទៈមិនអើពើទាំងភាពត្រឹមត្រូវខាងនីតិវិធី និងភាពយុត្តិធម៌ដ៏សំខាន់ ដោយគ្រាន់តែបិទភ្នែកធ្វើមិនដឹងដោយចេតនា។

**អាស្រ័យហេតុនេះ** តាមសំអាងហេតុទាំងអស់ខាងលើ មេធាវីការពារក្តីសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅអ្នកបកប្រែផ្ទាល់មាត់ដែលមានវត្តមាននៅក្នុងពេលការស្តាប់ចម្លើយ ភី ភួន លើកទីពីរដែលធ្វើឡើងដោយក.ស.ច.ស ដើម្បីផ្តល់ភ័ស្តុតាងនៅក្នុងសវនាការសួរដេញដោលផ្ទាល់មាត់ជាសាធារណៈ។

សូមលោកលោកស្រីចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

| | |
|---|---|
| អាង ឧត្តម | Michael G. KARNAVAS |

សហមេធាវីការពារក្តីលោក អៀង សារី

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជានា**ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២**